# ប្រឆាំងនឹងរបបផ្តាច់ការ

និពន្ធដោយលោកបណ្ឌិត ហ្គាហ្សារ ពាងម៉េត
ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨

**លោក រ៉ាល់ហ្វ៍ វ៉ាល់ដូ អេមើសុន ( Ralph Waldo Emerson )**

*មេដឹកនាំចលនា* transcendentalist *សតវត្សទី១៩* (*១៨០៣-១៨៨២*)

**«ពេលវេលាឥឡូវនេះ ក៏ដូចជាគ្រប់ពេលវេលាដែរ គឺជាពេលវេលាដ៏ល្អប្រសើរ ប្រសិនបើយើងដឹងថាតើយើងចង់យកពេលវេលានេះទៅធ្វើអ្វី» ។**

*ខ្ញុំបានសរសេរក្នុងអត្ថបទចុះថ្ងៃទី១២ ខែកម្ភៈ ក្រោមចំណងជើង «ដំណើរឆ្ពោះទៅថ្ងៃអង្សា» ថា បើយោងតាមគន្លងផ្លូវនយោបាយនៅកម្ពុជា ឆ្នាំ២០១៨នេះអាចជាឆ្នាំដែលចាប់ផ្តើមកំណត់ការស្លាប់រស់របស់ខ្មែរប្រជាធិបតេយ្យដែលត្រូវបានអំណាចផ្តាច់ការឡោមព័ទ្ធចង់ស្លាបសេក ហើយក៏អាចជាឆ្នាំដែលផ្តើមដំណើរឆ្ពោះទៅកាន់ថ្ងៃអង្សា (ពាក្យខ្មែរសាមញ្ញហៅថា ថ្ងៃអន្សា) របស់សម្តេចតេជោហ៊ុនសែន ដែលជាអតីតមេបញ្ជាការខ្មែរក្រហមបនប៉ុលពត និងជាមេបនអំណាចផ្តាច់ការដែរ ។ សំនួរសួរថា តើនរណានឹងបានទៅដល់ទីដៅមុន ។*

*ក្រុមសកម្មជនខ្មែរតស៊ូមតិប្រជាធិបតេយ្យត្រូវបង្កើតជំនឿយ៉ាងមាំដូចថ្មដាថា ១. គឺសកម្មជនខ្មែរទាំងអស់គ្នានេះហើយដែលជាភ្នាក់ងារនៃការកែប្រែផ្លាស់ប្តូរដែលគេចង់ឃើញ ២. របបផ្តាច់ការសម្តេចតេជោមានជើងដីឥដ្ឋដែលអាចដំឱ្យបែកខ្ទាយបាននិងអាចគាស់រំលំបានដែរ ។*

ទេវតាមិនដែលបានផ្តន្ទាទោសឱ្យខ្មែរយើងរស់ក្នុងទាសភាពជាអចិន្ត្រៃយទេ ។ រីឯជនផ្តាច់
ការវិញក៏មិនដែលបានទេវតាផ្តល់ឥទ្ធិពលឯណាឱ្យកាន់អំណាចរដ្ឋជារៀងរហូតដែរ ។ ក្រុម
សកម្មជនខ្មែរតស៊ូមតិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សក៏មិនដែលបានទេវតាដាក់ឱ្យនៅ
ខ្សោយតែរហូតឡើយ ។ ការកែប្រែផ្លាស់ប្តូរជាភាពអចិន្ត្រៃយតែមួយក្នុងជីវិត ។
អតីតប្រធានាធិបតីអាមេរិកាំងទី១៦ ឆ្នាំ ១៨៦១-១៨៦៥ លោក ធីអូដ័រ រ៉ូហ្សីវែល Theodore
Roosevelt បានរំឭកថា «ធនធានទាំងអស់ដែលយើងត្រូវការ វាស្ថិតនៅក្នុងគំនិតយើងរួច
ស្រេចទៅហើយ » ដូច្នេះ «ចូរអ្នកធ្វើអ្វីដែលអ្នកអាចធ្វើបានជាមួយអ្វីដែលអ្នកមាននៅក្នុង
ដៃអ្នកនៅគ្រប់ទីកន្លែងដែលអ្នកមានវត្តមាន » ។

របបគ្រប់គ្រងភ្នំពេញអាឡាអ័រវែល **1984** បានបញ្ចេញក្បាច់ក្បួរ «Minitrue» ធ្លីនក្អែកបំភាន់
សាធារណៈមតិ យកសធ្វើជាខ្មៅ ២+២=៥ ដូចជាក្នុងឆ្នាំ១៩៧០ ខ្មែរប្រឆាំងនឹងកងទ័ពយួន
ហាណូយ៤ម៉ឺនទៅ៦ម៉ឺននាក់ឈរនៅលើដីខ្មែរទំហំប្រមាណជា៣៥០០គីឡូម៉ែត្រការ៉េ
ចាប់ពីព្រំប្រទល់ខ្មែរ-យួនរហូតដល់តំបន់ទន្លេសាប «បងធំ» គេហៅថា «ជារដ្ឋប្រហារ» ។
រីឯរដ្ឋប្រហារបងធំបញ្ជាយោធាឱ្យវាយទ្រង់ ឬណារិទ្ធ រត់ចោលស្រុកនៅឆ្នាំ១៩៩៧
«ក្រសួងសច្ចៈ» គេហៅថាជាការកំទេច «រដ្ឋប្រហារ» របស់ក្រុមរាជានិយមទៅវិញ ។
នៅពេលបច្ចុប្បន្នកាលនេះ គេមិនចង់ឱ្យពលរដ្ឋបោះឆ្នោតដោយសេរីនិងដោយយុត្តិធម៌
«Minitrue» គេបង្កើតជាលេសថា គណៈបក្សជំទាស់បានធ្វើសន្និដ្ឋភាព
ឬភាពឃុបឃិតផ្សំគំនិតជាមួយបរទេសដើម្បីទម្លាក់រដ្ឋាភិបាលចេញពីអំណាច ។
បន្ទាប់មកគេបានបង្កើតច្បាប់រំលាយគណៈបក្សសង្គ្រោះជាតិប្រកបដោយប្រជាប្រិយភាព
ចោលចេញតែម្តង រួចគេ
ប្លន់យកអាសនៈទាំង៥៥ដែលរាស្ត្របានផ្តល់ទៅគណៈបក្សជំទាស់ព្រមទាំងដកហូតសិទ្ធិរប
ស់ក្រុមប្រឹក្សាឃុំសង្កាត់របស់គណៈបក្សជំទាស់ចំនួន៥០០៧នាក់ ក្នុងគោលបំណងមិន
ឱ្យអ្នកតំណាងរាស្ត្រគណៈបក្សជំទាស់៥៥នាក់និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់៥០០៧

នាក់អាចបោះឆ្នោតរើសសមាជិកព្រឹទ្ធសភានីតិកាលទី៤នៅថ្ងៃទី២៥កុម្ភៈមុននេះបាន ។ គេបានហាមខ្មែរ ១១៨ នាក់ទៀតមាននវត្តមានលើឆាកនយោបាយ ។

ក្បួនក្បាច់របបភ្នំពេញត្រូវបានអ្នកនិពន្ធដ៏ឆ្នើម គឺលោក ហ្សក អ័រវែល George Orwell (១៩០៣-១៩៥០) មើលឃើញច្បាស់តាំងពីជាង៧០ឆ្នាំមកហើយ ហើយលោកទាំងបានសរសេរជាប្រលោមលោក «*Nineteen Eighty-Four*» ឬ «**ដប់ប្រាំបួន-ប៉ែតសិបបួន**» ដែលខ្ញុំបានលើកយកមកពិពណ៌នាក្នុងអត្ថបទចុះថ្ងៃទី២៦ ខែកុម្ភៈ ស្ដីអំពីជីវិតស្ថិតនៅក្រោមអំណាចផ្ដាច់ការដែលយើងអាចមើលឃើញមាននៅជុំវិញពិភពលោកសព្វថ្ងៃនេះ ។

កាលពីពេលថ្មីៗនេះ លោក ហ្វីល រ៉ូប៊ើតសុន នៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch បានថ្លែងថា «ការគ្រប់គ្រងរបស់គណៈបក្សប្រជាជនកម្ពុជាមានន័យថា ការរឹបអូសយកដីធ្លីនិងការផ្លាស់ទីលំនៅ ការប្លន់យកធនធានជាតិ អំពើពុករលួយនិងសេវារដ្ឋាភិបាលគ្មានភាពស័ក្តិសិទ្ធិ យោធូបនីយកម្ម និងការចាប់ខ្លួននិងរំលោភសិទ្ធិជាច្រើន» ។ រដ្ឋាភិបាលខ្មែរអាឡាអ័រវែលសព្វថ្ងៃនេះជារដ្ឋាភិបាលអនាថាចរច្រប់លួចប្លន់ ពោលគឺមិនមែនជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និងសម្រាប់ប្រជាពលរដ្ឋទេ ហើយមិនត្រូវមាន «សិទ្ធិគ្រប់គ្រង» ប្រទេសជាតិដែរ ។

នៅក្នុងលិទ្ធិប្រជាធិបតេយ្យ (ដែល «បងធំ» បានកុហកប្រជាពលរដ្ឋខ្មែរថា «បងធំ» ពិតជាឱបក្រសោបមែន ) «សិទ្ធិគ្រប់គ្រង» the right to rule របស់រដ្ឋកិបាលត្រូវតែបានទទួលមកពីប្រជាពលរដ្ឋដែលបោះឆ្នោតផ្ដល់ «អំណាចគ្រប់គ្រង» ដល់រដ្ឋាភិបាលនោះ ។ វាទាល់តែប្រជាពលរដ្ឋបានផ្ដល់ «អំណាចគ្រប់គ្រង» ទើបរដ្ឋាភិបាលប្រជាធិបតេយ្យមាន «សិទ្ធិគ្រប់គ្រង» ហើយទើបប្រជាពលរដ្ឋត្រូវមានភារៈទទួលខុសត្រូវជាសីលធម៌ គោរពនិងស្ដាប់បង្គាប់ច្បាប់និងអំណាចបញ្ជារបស់រដ្ឋាភិបាល ។ ពោលគឺប្រជាពលរដ្ឋនោះឯងជាអ្នកធ្វើធម្មានុរូបកម្មបំពេញភាពត្រឹមត្រូវតាមច្បាប់ឱ្យរដ្ឋាភិបាល ។

ខ្ញុំបានបង្រៀនវិទ្យាសាស្ត្រនយោបាយនៅសកលវិទ្យាល័យលើកោះហ្គ័មសហរដ្ឋអាមេរិកចំនួន១៣ឆ្នាំ មាន២៨មាសក្នុងមួយឆ្នាំ ។ ក្រៅពីបង្ហាត់បង្រៀនមុខវិជ្ជាផ្សេងៗដែលមានរួម

ទាំងវិជ្ជាសិក្សា «អង្គការអន្តរជាតិនិងអង្គការសហប្រជាជាតិ» «ច្បាប់អន្តរជាតិ» «រដ្ឋាភិបាលនិងនយោបាយក្នុងពិភពទីបី » ខ្ញុំមានភារៈបង្ហាត់បង្រៀនវិទ្យាសាស្ត្រនយោបាយថ្នាក់ដំបូង ១០១ ចំនួន ១ ម៉ោង ២០ នាទីក្នុងមួយថ្នាក់ចំនួនពីរទៅបួនថ្នាក់ក្នុងមួយថ្ងៃ ចំនួនពីរថ្ងៃក្នុងមួយអាទិត្យ ចំនួនប្រាំខែក្នុងមួយឆមាស ។ ខ្ញុំធ្លាប់បានទទួលរង្វាន់ «ឧត្តមភាពផ្នែកបង្ហាត់បង្រៀន» ដែរ ។

សូមជំរាបថាគឺនៅក្នុងថ្នាក់ដំបូង ១០១ ដែលខ្ញុំបានចំណាយពេលរុកអង្រួនខួរក្បាលនិស្សិតអាមេរិកាំងនិងអន្តរជាតិអំពី «សិទ្ធិគ្រប់គ្រង» របស់រដ្ឋាភិបាលប្រជាធិបតេយ្យ ។ ខ្ញុំបានសរសេរចងក្រងជាក្បួនសៀវភៅចែកចាយដល់សិស្សផងអំពី «មូលដ្ឋានប្រាំបួនដែលសំខាន់បំផុតនៅក្នុងលទ្ធិប្រជាធិបតេយ្យតំណាងរាស្ត្រនៅសហរដ្ឋអាមេរិក» ។ មូលដ្ឋានទី៨ក្នុងក្បួនសៀវភៅមានចំណងជើងថា «សិទ្ធិជំទាស់និងមិនស្តាប់បង្គាប់» ស្តីពីលោក ថូម៉ាស ហ្វេហ្វឺសុន Thomas Jefferson (១៧៤៣-១៨២៦) ដែលជាបិតាស្ថាបនិកសហរដ្ឋអាមេរិកម្នាក់ហើយនិងជាអ្នកនិពន្ធចម្បងនៃ «សេចក្តីថ្លែងការណ៍ប្រកាសឯករាជ្យ» សហរដ្ឋអាមេរិកឆ្នាំ ១៧៧៦ ។ លោកជាអតីតប្រធានាធិបតីអាមេរិកាំងទី៣ ពីឆ្នាំ ១៨០១ ដល់ ១៨០៩ ។ នៅក្នុង «សេចក្តីថ្លែងការណ៍ប្រកាសឯករាជ្យ» លោក ហ្វេហ្វឺសុន បានធ្វើការអធិដ្ឋានថា រដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីបំរើប្រជាពលរដ្ឋដែលមានសិទ្ធិតស៊ូមិនទទួលស្តាប់បង្គាប់បញ្ជារបស់រដ្ឋាភិបាលដែលមិនបំរើឆន្ទៈប្រជាពលរដ្ឋ ។ គំនិតនេះគឺផ្ទុយស្រឡះពីគោលការណ៍នៃរបបតំបន់ អូសេអានី ក្នុងប្រលោមលោក ***1984*** ដែលវាមានលក្ខណៈប្រហាក់ប្រហែលនឹងរដ្ឋាភិបាលខ្មែរបច្ចុប្បន្នដែរ ។

ដោយហេតុថា នៅក្នុងលិទ្ធិប្រជាធិបតេយ្យគឺប្រជាពលរដ្ឋដែលជាប្រភពនៃអំណាច ដរាបណាប្រជាពលរដ្ឋខ្លួនឯងនៅមិនទាល់យល់និងនៅមិនទាន់ជឿទេថា អំណាចគឺពិតជាមាននៅក្នុងកណ្តាប់ដៃខ្លួនឯងរួចជាស្រេចមកហើយ ដរាបនោះ «អំណាចប្រជាពលរដ្ឋ» ឬ people power ឥតមានទីកន្លែងទេ ។

យើងត្រូវចាំថាជនដឹកនាំផ្តាច់ការឥតមានមុខរបរដែលជននោះអនុញ្ញាតឱ្យប្រជាពលរដ្ឋ

*បោះឆ្នោតដោយសេរី ដោយយុត្តិធម៌ និងដោយសម្ងាត់ដើម្បីដកហូតពួកគេ -- ដែលពលរដ្ឋបានឃើញថាមិនបានបំរើធនុះនិងផលប្រយោជន៍របស់ពលរដ្ឋ -- ចេញពីកំពូលបល្ល័ង្កត្រួតត្រាឡើយ ។*
*គោលបំណងធំបីនៃរដ្ឋាភិបាលក្នុងលោកគឺ ១. ការពារឯករាជ្យនិងអធិបតេយ្យ ២. បង្កើតស្ថិរភាព (សណ្ដាប់ធ្នាប់និងសន្តិសុខ) ក្នុងសង្គម ៣. ជម្រុញនិងលើកដំកើងសុខុមាលភាពបុគ្គលនិងសុខុមាលភាពសាធារណៈ ។ ចំពោះរដ្ឋាភិបាលប្រជាធិបតេយ្យ គេតែងតែថ្លឹងបញ្ហាសណ្ដាប់ធ្នាប់និងសន្តិសុខជាមួយនឹងបញ្ហាសេរីភាពនិងសិទ្ធិមនុស្ស តែរបប **1984** គេស្វែងរក «អំណាច» និង «ផលប្រយោជន៍ផ្ទាល់ខ្លួនជូន «គណៈបក្សក្នុង» និងជូន «បងធំ» -- កត្តាទាំងនេះមានភាពស្រដៀងគ្នានឹងរបបខ្មែរបច្ចុប្បន្នដែរ ។*

**លោក ធីអូដ័រ រ៉ូហ្ស៊ីវែល** (Theodore Roosevelt)

*អតីតប្រធានាធិបតីអាមេរិកាំងទី២៦ (១៩០១-១៩០៩)*

«**សណ្ដាប់ធ្នាប់ដោយគ្មានសេរីភាពនិងសេរីភាពដោយគ្មានសណ្ដាប់ធ្នាប់ គឺជាការបំផ្លាញស្មើៗគ្នា**» ។

**លោក ជេម្មស៍ គ្យូ វិលសុន** (James Q. Wilson)

*អតីតសាស្ត្រាចារ្យអាមេរិកាំងផ្នែកវិទ្យាសាស្ត្រនយោបាយ ១៩៣១-២០១២*

«**បើគ្មានសេរីភាពទេ ច្បាប់ត្រូវបាត់បង់លក្ខណៈនិងឈ្មោះរបស់វា ហើយក្លាយទៅជាការកៀបសង្កត់** ។

**បើគ្មានច្បាប់ទេ សេរីភាពត្រូវបាត់បង់លក្ខណៈនិងឈ្មោះរបស់វា ហើយក្លាយទៅជាការប្រាសចាកសីលធម៌**» ។

*ទោះម្ដេចក្ដី «អំណាចប្រជាពលរដ្ឋ» មិនមែនមិនអាចឈានដើរដល់ប្រទេសកម្ពុជាទេ ។ ក្រុមសកម្មជនខ្មែរតស៊ូមតិប្រជាធិបតេយ្យ សេរីភាព និងយុត្តិធម៌ត្រូវចាំបាច់ជឿថា ការកែប្រែផ្លាស់ប្ដូរគឺអាចធ្វើទៅបាន ។ បើគ្មានជំនឿទេ តើខ្មែរយើងនៅសល់អ្វីក្រៅពីរបប **1984**?* អ្នកតស៊ូប្រឆាំងម្នាក់នឹងរបបផ្ដាច់ការបានជូនជាទស្សនៈមួយថា ជនផ្ដាច់ការដែលនៅតែអាចកាន់អំណាចផ្ដាច់ការតទៅទៀតបាន គឺមកពីគេមានជោគជ័យក្នុងកៀបសង្កត់ប្រជាពលរដ្ឋដែលជាប្រភពនៃអំណាច ឱ្យគោរពប្រតិបត្តិស្ដាប់បង្គាប់គេ (obey) ឱ្យដាក់ខ្លួនជាចំណុះហើយចុះចូលនឹងគេ (submit) និងឱ្យព្រមធ្វើកិច្ចសហប្រតិបត្តិការជាមួយគេ (cooperate) – ឬ OSC ជាពាក្យកាត់ខ្លីដើម្បីងាយស្រួលចាំ ។ អ្នកតស៊ូដដែលរូបនេះបានសួរថា បើជនផ្ដាច់ការនៅត្រួតត្រាបានដោយសារប្រជាពលរដ្ឋសុខចិត្តប្រគល់ OSC ទៅឱ្យគេ ចុះបើប្រជាពលរដ្ឋបដិសេធ OSC វិញ តើជនផ្ដាច់ការនឹងអាចបន្តអំណាចផ្ដាច់ការយ៉ាងណាទៀតបាន ?

តែជាការអកុសលដែលខ្មែរយើងត្រូវបានរស់នៅក្រោមវប្បធម៌មួយដែលទម្លាប់ខ្មែរច្រើនរយឆ្នាំ -- ទម្លាប់ដែលបានក្លាយទៅជាប្រពៃណីពិសិដ្ឋរហូតដល់សព្វថ្ងៃនេះ -- ឱ្យ «គោរព» «បំរើ» «ការពារ» «ស្មោះត្រង់» នឹងបុគ្គលដឹកនាំរហូតផុតជីវិត ។ (គួររំឭកដែរថា កាលលោកស្រី ហ៊ីលឡារី គ្លីនតុន Hillary Clinton នៅធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកាំង លោកស្រីធ្លាប់បានទូន្មានខ្មែរប្រជាធិបតេយ្យនៅគេហដ្ឋានលោកស្រីថា សូមឱ្យរួបរួមគ្នាជាធ្លុងមួយនៅជុំវិញគោលការណ៍និងវេទិកានយោបាយទូលំទូលាយ ជាជាងនៅក្រោមបុគ្គលដឹកនាំរូបណាម្នាក់ ដើម្បីប្រយុទ្ធប្រឆាំងនឹងរបបគ្រប់គ្រងផ្ដាច់ការ ។)

តែប្រពៃណីខ្មែររយឆ្នាំបានបត់បែនខ្មែរឱ្យគោរពប្រតិបត្តិទំនៀមទម្លាប់ -- ទម្លាប់ស្វ័យប្រវត្តទម្លាប់បន្តពូជ ទម្លាប់ធ្វើនិងគិតអ្វីដូចដែលធ្លាប់បានធ្វើនិងគិតតាមវិធី «អូតូម៉ាទីក» ដោយមិនបាច់ប្រើបញ្ញា គ្រាន់តែចុច «ប៊ូតុង» ទៅបានហើយ ។ យ៉ាងនេះ ប្រពៃណីរយឆ្នាំបានដាក់ទុកខ្មែរក្នុងទ្រុងសេរភាព ទាំងខ្លួនមនុស្ស ទាំងផ្នត់គំនិតខួរក្បាលមិនឱ្យអាចរង្គើឃ្លាតចេញពីខ្សែបន្ទាត់ដែលអនុញ្ញាត ធ្វើឱ្យរាំងស្ទះដំណើរគិតគូរ «ក្រៅប្រអប់» គិតគូរឱ្យបានខុសពីមុន

បង្កើតជាឧបសគ្គដល់ការត្រិះរិះពិចារណានិងការស្រមើស្រមៃច្នៃប្រឌិតដែលវាចាំបាច់សំរាប់ការអភិវឌ្ឍន៍និងវឌ្ឍនភាព ។

ពោលគឺវប្បធម៌រយឆ្នាំនេះហើយដែលជួយសម្រួលឱ្យរបបផ្តាច់ការជិះជាន់ពលរដ្ឋដែលរស់នៅក្នុងទម្លាប់ឱ្យគេជិះលើខ្នងជារៀងរហូតមក ។ ខ្មែរត្រូវតែដកឫសគល់នៃវប្បធម៌រយឆ្នាំនេះចេញ បើខ្មែរចង់ឃើញមានការកែប្រែផ្លាស់ប្តូរនៅក្នុងសង្គម -- បើទម្លាប់នៅជាមួយសត្វគោដែលនាំយើងឱ្យដេកពេលយើងត្រូវឧស្សាហ៍ ម្តេចឡើយយើងមិនបង្កើតទម្លាប់នៅជាមួយសេកដែលវានាំយើងឱ្យហោះហើរ ? ឬមួយយើងមិនចង់កែទម្លាប់ ?

ការកែប្រែផ្លាស់ប្តូរត្រូវចាប់ផ្តើមដោយបុគ្គលមនុស្សដែលសម្លឹងមើលទៅក្នុងកញ្ចក់ឆ្លុះគឺរូបអ្នកនិងរូបខ្ញុំ ។

ខណៈពេលដែលកូនក្មេងខ្មែរត្រូវបានទទួលការបង្ហាត់បង្រៀនអំពី «គុណធម៌ » នៃប្រពៃណីរយឆ្នាំដូចបានពោលខាងលើ កូនក្មេងអាមេរិកាំងត្រូវបានទទួលការបង្ហាត់បង្រៀនឱ្យយល់និងជឿទៅលើ «សេចក្តីពិតច្បាស់ក្រឡែតដែលគេមិនអាចបដិសេធបាន» ហើយឱ្យគេសុខចិត្តតស៊ូនៅពេលដែល «ជីវិត សេរីភាព និងការស្វែងរកសុភមង្គល» ត្រូវបានទទួលការគំរាមកំហែង ។

វាជាការពិតហើយថា ទម្លាប់ជាទង្វើមួយមិនមែនងាយស្រួលនឹងកែទេ ។ តែបើយើងធ្វើអ្វីមួយជាច្រើនដង ដូចជាយើងមិនព្រមបើកសៀវភៅអានអ្វីសោះ ទង្វើនេះវាក្លាយទៅជាទម្លាប់ខ្ជិល ។ តែយើងក៏អាចទម្លាប់បើកសៀវភៅអានជារៀងរាល់រាត្រីបានដែរ នេះវាក្លាយទៅជាទម្លាប់ល្អ ។

**លោក អារីស្តូត (Aristotle)**

បិតាស្ថាបនិកនៃអរិយធម៌លោកខាងលិច (៣៨៤ មគស-៣២២ មគស)

**«យើងគឺជាផលិតនៃទង្វើដែលយើងបានធ្វើម្តងហើយម្តងទៀត ។
ឧត្តមភាពមិនមែនជាទង្វើទេ ឧត្តមភាពគឺជាទម្លាប់មួយ» ។**

ខ្មែរយើងជាមនុស្សមានទម្លាប់ខ្លាច ។ វប្បធម៌រយឆ្នាំបានពង្រឹងការខ្លាចនេះទ្វេឡើងទៀត ។ នៅក្នុងគំនិតបំផុសបំផុលខ្មែរប្រជាធិបតេយ្យក្នុងការតស៊ូប្រឆាំងនឹងរបបផ្តាច់ការ (ខ្ញុំស្អប់ខ្ពើមគំនិតនិងទង្វើដែលជិះជាន់គំនិតតាំងពីខ្ញុំនៅក្មេងរហូតខ្ញុំនៅក្នុងជួរណៈសិស្សតស៊ូនិងនៅលើឆាកនយោបាយជាតិនិងអន្តរជាតិ ) ខ្ញុំតែងតែលើកយករឿងពិតផ្សេងៗមកនិទានជួយណែនាំអ្នកជិតឆ្ងាយឱ្យចំណាយពេលទំនេរមើលខ្សែភាពយន្តនានា ដូចជាខ្សែភាពយន្តគំនូរកំប្លែង Chicken Run ស្តីពីសត្វមាន់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វដែលវាសំរេចស្វែងរកមធ្យោបាយរត់ចេញដើម្បីរកសេរីភាព («ឬមួយយើងនឹងស្លាប់ជាមាន់សេរី ឬមួយយើងនឹងស្លាប់ក្នុងការតស៊ូដើម្បីជាមាន់សេរី» បញ្ចាំងផ្សាយក្នុងឆ្នាំ២០០០) ខ្សែភាពយន្ត Invectus ស្តីពីរឿងពិតនៃជីវិតតស៊ូរបស់លោក Nelson Mandela ដែលជាសកម្មជនប្រឆាំងនឹងរបបរើសអើងប្រកាន់ពូជសាសន៍នៅប្រទេសអាហ្វ្រិកខាងត្បូង (បញ្ចាំងផ្សាយក្នុងឆ្នាំ២០០៩) ខ្សែភាពយន្ត Robin Hood ស្តីពីអ្នកច្បាំងដើងចាស់ក្នុងសម័យសតវត្សទី១២ ដែលលោកបានដឹកនាំប្រជារាស្រ្តបះបោរប្រឆាំងនឹងរាជបល្ល័ងនៅក្នុងតំបន់មួយនៅប្រទេសអង់គ្លេសបុរាណដែលទទួលរងអំពើពុករលួយនិងអំពើឃោរឃៅ បញ្ចាំងផ្សាយក្នុងឆ្នាំ ២០១០) ។ ខ្សែភាពយន្តទាំងនេះជាខ្សែភាពយន្តដែលបានបំផុសបំផុលស្មារតីតស៊ូរបស់ខ្ញុំមិនឱ្យផុងចុះទោះសភាពការណ៍វាទំនងហាក់ដូចជាងងឹតខ្លាំងក្តី។

សូមរំលឹកនូវកំណាព្យមួយរបស់ម្ចាស់ មិតតែយ៉ា ដែលខ្ញុំធ្លាប់បានយកមកផ្សាយជាច្រើនដងដែលមានខ្លឹមសារថា ៖ «លុះដល់ពេលគេប្រឹងសង្កត់សង្កិនហើយគេរកផ្លូវកំទេចអ្នកចូរអ្នកងើបឡើង ងើបហើយងើបទៀត ដូចសត្វ ហ្វីនីក Phoenix ងើបចេញពីផេះភ្លើងងើបឡើងរហូតដល់សត្វចៀមក្លាយទៅជាសត្វសឹង្ហ រហូតដល់សភាពងងឹតសូន្យឈឹងត្រូវរលត់បាត់អស់» ។

ខ្មែរអ្នកអានម្នាក់នៅសហរដ្ឋអាមេរិកបានបង្ហោះពាក្យពេជន៍លើអ៊ិនធឺណេតនិយាយចំអកថា «សត្វចចកឬសត្វមាន់មិនអាចក្លាយទៅជាសត្វសឹង្ហបានទេ » ។ ពាក្យសំដីនោះធ្វើឱ្យ

ខ្ញុំចុកក្នុងខ្លួនដោយនឹកគិតថាអ្នកសរសេរនោះដែលមើលឃើញខ្មែរមិនហួសពីសត្វចចកឬសត្វមាន់ គឺគាត់មិនបានផ្តល់ក្តីសង្ឃឹមថា ខ្មែរអាចក្លាយទៅជាសត្វសឹង្ហបានទេ ។ នៅក្នុងប្រវត្តិសាស្ត្រខ្មែរមាន «សឹង្ហ» ខ្មែរដែលបានបញ្ចេញស្នាដៃយ៉ាងក្លាហាននៅលើសមរភូមិដែរ ។ ខ្ញុំធ្លាប់បានឮគេនិយាយថា ខ្មែរជាមនុស្ស «បាក់ស្បាត» ក៏ប៉ុន្តែខ្ញុំមិនដែលយល់ដូចគេបានថានោះឡើយ ។ ផ្ទុយទៅវិញ ខ្ញុំបានដឹងថាបើចាក់ចំគន្ទឹះ ខ្មែរអាចជាមនុស្សដែលគេទប់មិនឈ្នះទេ ។

ខ្ញុំនឹកស្រណោះដល់កង្វះយ៉ាងសម្បើមក្នុងចំណោមខ្មែរយើងនូវគំនិតត្រិះរិះពិចារណា គំនិតស្រមើស្រមៃ ច្នៃប្រឌិតស្វែងរកមធ្យោបាយប្រឆាំងនឹងរបបសង្កត់សង្កិន ។ យើងជាបុគ្គលមនុស្សខ្មែរដែលមានខួរមួយគីឡូក្រាមអាចធ្វើការច្នៃប្រឌិត គំនិតស្មារតីយើងមិនមែនត្រូវបានចារកែមិនរួចនោះទេ ។ ទម្លាប់កើតមកពីទង្វើ ធ្វើម្តងហើយម្តងទៀតយូរៗទៅទើបទម្លាប់កើតទៅជាប្រពៃណី ។ យើងជាបុគ្គលមនុស្សហើយបុគ្គលមនុស្សអាចរៀន ធ្វើអ្វីបានគ្រប់យ៉ាង ឱ្យតែយើងចង់រៀន ។ គំនិត ស្មារតី អាកប្បកិរិយាអាចបណ្តុះបណ្តាល វិញ្ញាញ្ញឱ្យបានទៅជាយ៉ាងណាមួយដោយសារការរៀនសូត្រ ។

ប្រវត្តិសាស្ត្រពិភពលោកបានបង្ហាញឱ្យឃើញរួចមកហើយថា គ្មានអ្វីដែលមនុស្សលោកធ្វើមិនបាននោះទេ បើគេប្តេជ្ញាចិត្តនិងបង្កើតឆន្ទៈថាធ្វើ ។ ពាក្យពេជន៍លោកឧត្តមសេនីយ៍ ស៊ុនត៍ស៊ូ (៥៤៤ មុន គ.ស.-៤៩៦ មុន គ.ស.) នៃប្រទេសចិនបុរាណដែលយោធាក្នុងលោកព្រមទាំងយោធាបស្ចឹមប្រទេសផងបានយកទៅបង្រៀននាយទាហានរបស់គេបានចែងថា «កំពូលនៃសិល្បៈសង្គ្រាមគឺបង្រ្កាបសត្រូវដោយមិនបាច់ប្រយុទ្ធគ្នា» បង្ហាញឱ្យឃើញអំពីសារៈសំខាន់នៃគំនិត ។ ខ្ញុំក៏បាននឹកទៅដល់ខ្សែភាពយន្ត Robin Hood ត្រង់កន្លែងកាលសម័យអ្នកចម្បាំងដើងចាស់នោះនៅពីក្មេង ឪពុករបស់គាត់ក៏ធ្លាប់បានដឹកនាំប្រជារាស្ត្រប្រឆាំងនឹងការសង្កត់សង្កិនរបស់របបពុករលួយដែរ ហើយឪពុកគាត់បានត្រូវគេយកទៅប្រហារជីវិតដោយប្រើដាវរាជបល្ល័ង ។ ឪពុកគាត់បានធ្វើចារិកនៅលើថ្មដែលគេលាក់ទុក

និងលើដងដាវថា «ចូរអ្នកក្រោកឡើង ក្រោកហើយក្រោកទៀត រហូតដល់សត្វចៀមក្លាយទៅជាសត្វសឹង្ហ» ។

ការប្រយុទ្ធប្រឆាំងនឹងរបបផ្តាច់ការនៅភ្នំពេញបានឈានមកដល់ឆាកសង្គ្រាមផ្លូវគំនិតហើយ បើយើងមិនយកគំនិតមកប្រើទេ ថ្ងៃអង្វាន់នឹងនៅចាំនៅខ្លោងទ្វារខាងមុខនេះ ។

អ្នកជំនាញការម្នាក់ក្នុងការតស៊ូប្រឆាំងនឹងរបបសង្កត់សង្កិនយល់ថា មនុស្សដែលប្រគល់ OSC ឱ្យជនផ្តាច់ការណាម្នាក់គឺជាមនុស្ស «ស្ម័គ្រចិត្ត» ពោលគឺគេសុខចិត្តគោរពប្រតិបត្តិស្តាប់បង្គាប់ជនផ្តាច់ការ សុខចិត្តដាក់ខ្លួនជាចំណុះនិងចុះចូលជាមួយជនផ្តាច់ការ និងសុខចិត្តធ្វើសហប្រតិបត្តិការជាមួយជនផ្តាច់ការ -- ប្រហែលដោយចង់បានរង្វាន់អ្វីម៉្យាងឬត្រូវការបំពេញ «ផលប្រយោជន៍ផ្ទាល់ខ្លួន» អ្វីមួយដោយអាចគិតឃើញថា បើមិនស្តាប់បង្គាប់ មិនចុះចូល មិនសហការទេ ក្រែងវាមានផលវិបាកអ្វីម៉្យាងអាចកើតមានឡើង ។ យ៉ាងនេះហើយបានជាយើងឃើញមាន៖ មនុស្ស «គិតទ្វេភាគ» double thinkers ដែលស្អប់ខ្ពើមរបបផ្តាច់ការតែក្នុងគំនិតតែក្បាលក្រៅឱនលំទោន មនុស្សនៅក្នុងវិស័យ «ព្រងើយកន្តើយនិងឥតរវល់» មនុស្ស «ចាំបាយធ្មឹន» មនុស្ស «ជិះដោយឥតបង់កម្រៃ» ។ល។ អ្នកទាំងនេះព្យាយាមអត់ឱនមើលរំលងកន្លែងមិនសូវស្អាតល្អរបស់ជនផ្តាច់ការហើយខំតែស៊ូទ្រាំទៅ ។

គេឃើញមានអ្នកជំនាញការផ្នែកតស៊ូម្នាក់ទៀតបានសរសេរអំពីសំណេររបស់អ្នកនិពន្ធបរទេសពីររូបដែលវាអាចមានប្រយោជន៍សំរាប់ខ្មែរយើងទាំងអស់គ្នាយកមកគិតបន្តិច ។ អ្នកនិពន្ធដ៏ល្បីឈ្មោះជាតិរុស្ស៊ី លោក ឡេវ តូលស្តូយ Leo Tolstoy ១៨២៣-១៩១០ បានលើកយកបញ្ហាប្រទេសអង់គ្លេសកៀបសង្កត់លើពលរដ្ឋឥណ្ឌាធ្វើជាសំនួរសួរថា ៖ «ចុះវាមានន័យដូចម្តេចដែលថា (ក្រុមហ៊ុនពាណិជ្ជកម្មអង់គ្លេសមួយ) មានមនុស្សបីពាន់នាក់ . . . អាចកៀបសង្កត់លើមនុស្សពីររយលាននាក់ . . ?

តើតួលេខនេះមិនបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ទេឬថា វាមិនមែនជនជាតិអង់គ្លេស (ប៉ុន្មានពាន់នាក់) អាចទៅដាក់ទាសកម្មលើជនជាតិឥណ្ឌា (រយលាននាក់) ឯណា

គឺជនជាតិឥណ្ឌា (ពីររយលាននាក់) ទេតើដែលបានដាក់ខ្លួនធ្វើជាទាសករជនជាតិអង់គ្លេស (ចំនួនបីពាន់នាក់) នោះ?» ។

វាមានស្ថាបនិកទស្សនៈវិជ្ជានៅប្រទេសបារាំងម្នាក់គឺលោក អេចេន ដឺ ឡា បុទ្ធី Etienne de La Boetie ១៥៣០-១៥៦៣ បានពោលតាំងពីសតវត្សរ៍ទី១៦ម៉្លេះអំពីអំណាចនៃអ្នកសង្កត់សង្កិន ៖ «បុគ្គលដែលធ្វើបាបអ្នកគឺមានភ្នែកតែពីរប៉ុណ្ណោះ មានដៃតែពីរដែរ ហើយមានជង់ខ្លួនតែមួយ បុគ្គលនេះគ្មានអ្វីផ្សេងក្រៅពីមានតែខ្លួនតែម្នាក់ឯងនៅក្នុងនគររបស់អ្នក គឺគ្មានអ្វីក្រៅពីអត្ថប្រយោជន៍ដែលរូបអ្នក (ជាម្ចាស់នគរ) បានផ្តល់ទៅឱ្យបុគ្គលនេះដើម្បីឱ្យគេកំទេចខ្លួនអ្នកចោលតែប៉ុណ្ណោះ» ។

ខ្ញុំសូមបញ្ចប់អត្ថបទនេះដោយជូនជាទស្សនៈមួយសំរាប់ការគិត ៖ ការតស៊ូប្តេជ្ញាទប់ទល់មិនព្រមចុះញ៉មនឹងការបង្រ្កាបរបស់ជនផ្តាច់ការត្រូវតែផុះចេញពីក្នុងប្រទេស ។ ការតស៊ូមិនចុះញ៉មនឹងទាក់ទាញការយកចិត្តទុកដាក់ពីសំណាក់ពិភពលោកនឹងកូរសេចក្តីអាណិតអាសូរនិងសមានចិត្ត ហើយនៅទីបំផុតវានឹងទាក់ទាញការគាំទ្រពីពិភពលោក ។ អ្នកតស៊ូម្នាក់នៅក្នុងសតវត្សទី១៩ បានទូន្មានអ្នកតស៊ូរំដោះខ្លួនចេញពីរបបផ្តាច់ការថា ការតស៊ូរំដោះតម្រូវជាចាំបាច់ឱ្យខ្លួនទីពឹងខ្លួន ។

**លោក ហ្សក៌ច អ័រវែល (George Orwell)**

*ឈ្មោះដើម Eric Arthur Blair អ្នករះគន់ជាតិអង់គ្លេស ប្រឆាំងនឹងរបបផ្តាច់ការ ១៩០៣-១៩៥០*

**«ប្រសិនបើមានមនុស្សចំនួនច្រើនចង់បានសេរីភាពក្នុងការបញ្ចេញយោបល់ គេនឹងមានសេរីភាពក្នុងការបញ្ចេញមតិ ទោះបីជាមានច្បាប់ហាមឃាត់ក៏ដោយ ។ ប្រសិនបើមតិសាធារណៈនៅស្ងាត់ស្ងៀមមិនកម្រើកទេ ជនភាគតិចដែលគេមិនត្រូវចិត្ត នឹងត្រូវទទួលរងការធ្វើទុក្ខបុកម្នេញ ទោះបីមានច្បាប់សំរាប់ការពារពួកគេក៏ដោយ»**

**អំពីអ្នកនិពន្ធ៖** *លោកបណ្ឌិត ហ្គាហ្វារ ពាងម៉េត អតីតយុទ្ធជនកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ* (*ឆ្នាំ១៩៨០-១៩៨៩*) *បានបង្រៀនវិទ្យាសាស្រ្តនយោបាយចំនួន១៣ឆ្នាំ នៅសាកលវិទ្យាល័យកោះ* Guam (*ឆ្នាំ១៩៩១-២០០៤*) *។ លោកបានចូលនិវត្តន៍ក្នុងឆ្នាំ២០០៤ ហើយបច្ចុប្បន្ននេះរស់នៅក្នុងសហរដ្ឋអាមេរិក។ លោកអ្នកអាចទាក់ទងនឹងលោកបានតាមរយៈសារអេឡិចត្រូណិច* (e-mail) peangmeth@gmail.com